ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

## សូមគោរពជូន
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ២០២១ ខាងមុខនេះ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនាគោរពនិងដឹងគុណយ៉ាងជ្រាលជ្រៅបំផុត និងសូមជូននូវសព្ទសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរគ្រប់ប្រការជូនចំពោះ **សម្តេចក្រឡាហោម និងលោកជំទាវ** ។

ក្នុងឱកាសដ៏មហាប្រសើរនេះ យើងខ្ញុំទាំងអស់សូមសម្តែងនូវគារវកិច្ចគោរពដឹងគុណដ៏ស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចក្រឡាហោម** នៅក្នុងបេសកកម្មដឹកនាំក្រសួងមហាផ្ទៃ ដើម្បីបន្តថែរក្សាការពារបានសុខសន្តិភាព ស្ថិរភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ការពង្រឹងលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការអនុវត្តន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅចូលរួមជាឧត្តមប្រយោជន៍សាធារណៈដ៏ធំធេង សម្រាប់សង្គមជាតិ និងប្រជាជននៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏សោមនស្សរីករាយនេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **សម្តេចក្រឡាហោម លោកជំទាវ បុត្រា បុត្រី និង ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូណ៌ និងទទួលបាននូវពុទ្ធពរមហាប្រសើរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២០

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**